**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
*លេខៈ ១៩ សសរ*

# សេចក្តីសំរេច
## ស្តីពី
## ការកែសំរួលប្រធានគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញសេចក្តីសំរេចលេខ០៣ស.សរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣

-ផ្អែកតាមការចាំបាច់

## <u>សំ រេ ច</u>

**<u>ប្រការ១:</u>** ត្រូវបានតែងតាំងឯកឧត្តម ឧត្តមនេសីយ៍ឯក **នេត្រ សាវឿន** អគ្គស្នងការរងនគរបាលជាតិ ជាប្រធាននៃគណៈកម្មការស្រាវជ្រាវអំពើហិង្សា ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិ ប្រជាពលរដ្ឋ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ជំនួសឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

**<u>ប្រការ២:</u>** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គ្រប់ប្រធានក្រសួង ស្ថាប័ន និងឯកឧត្តម អស់លោកក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០០៣

**ជ.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

<u>*ចម្លងជូន*</u>

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីស ខេង*

*-ក្រសួងមហាផ្ទៃ*

*-ក្រសួងការពារជាតិ*

*-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*

*-អគ្គស្នងការដ្ឋាននគរបាលជាតិ*

*-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*

*-ដូចប្រការ១*

*-ឯកសារ-កាលប្បវត្តិ*